# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ក្រសួងមហាផ្ទៃ | ក្រសួងផែនការ |
|---|---|---|

លេខ ១២៧ ស.អ.យ.ប្រ.ក

ថ្ងៃព្រហស្បតិ៍ ១រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០

## ប្រកាសអន្តរក្រសួង

## ស្តីពី

## ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និង កុមារអាយុក្រោម២ឆ្នាំ

| រដ្ឋមន្ត្រី | ឧបនាយករដ្ឋមន្ត្រី | ទេសរដ្ឋមន្ត្រី |
|---|---|---|
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | រដ្ឋមន្ត្រីក្រសួងផែនការ |

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ២៤៥ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ។

# សម្រេច

**ប្រការ១.-**

ប្រកាសអន្តរក្រសួងនេះមានគោលបំណងចូលរួមលើកកម្ពស់សុខុមាលភាពមាតា និងទារក ព្រមទាំងរួមចំណែកដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភរបស់កុមារ ក្នុងគ្រួសារក្រីក្រ ចាប់តាំងកូនក្នុងផ្ទៃរហូតដល់អាយុ២ឆ្នាំ ដើម្បីជំរុញការលូតលាស់ ទាំងកាយសម្បទា និងបញ្ញាស្មារតី។

**ប្រការ២.-**

ប្រកាសអន្តរក្រសួងនេះមានគោលដៅកំណត់អំពីយន្តការ និងការទទួលខុសត្រូវរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងមហាផ្ទៃ និងក្រសួងផែនការ ក្នុងការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ឱ្យមានប្រសិទ្ធភាព។

**ប្រការ៣.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងមហាផ្ទៃ និងក្រសួងផែនការសហការក្នុងការអភិវឌ្ឍសមត្ថភាពមន្ត្រីកម្មវិធីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងគាំទ្រការអនុវត្តកម្មវិធី ស្របតាមសៀវភៅប្រតិបត្តិគោលស្ដីពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ។

**ប្រការ៤.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងផែនការត្រូវផ្ដល់តាប្លែត(Tablets) ដល់រដ្ឋបាលឃុំ សង្កាត់ ដូចមានចែងក្នុងឧបសម្ព័ន្ធ១។

រដ្ឋបាលឃុំ សង្កាត់នីមួយៗ ត្រូវទទួលបានតាប្លែតចំនួនមួយគ្រឿងសម្រាប់ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ និងការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ តាមការស្នើសុំ។

តាប្លែតដែលផ្ដល់ជូនឃុំ សង្កាត់នេះត្រូវស្ថិតនៅក្នុងបញ្ជីសារពើភ័ណ្ឌរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងផែនការ។

**ប្រការ៥**.-

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាទទួលខុសត្រូវលើការចំណាយលើការជួសជុលតាប្លេតដែលបានផ្តល់ជូនឃុំ សង្កាត់សម្រាប់ (១) ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ និង (២) ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រតាមការស្នើសុំ។

**ប្រការ៦**.-

ក្រសួងផែនការត្រូវផ្តល់ទិន្នន័យអត្តសញ្ញាណគ្រួសារក្រីក្រដែលមានសុពលភាពជាប្រចាំ និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ដើម្បីបញ្ចូលទិន្នន័យអត្តសញ្ញាណគ្រួសារក្រីក្រទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានរបស់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ។

**ប្រការ៧**.-

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងផែនការសហការជាមួយក្រសួងមហាផ្ទៃដាក់ចេញគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងតាប្លេត( Tablet ) ដើម្បីគ្រប់គ្រងតាប្លេតឱ្យមានប្រសិទ្ធភាពដូចមានចែងក្នុងឧបសម្ព័ន្ធ២ ។

**ប្រការ៨**.-

អភិបាលរាជធានី ខេត្ត ត្រូវដឹកនាំ និងសម្របសម្រួលជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មន្ទីរសុខាភិបាល មន្ទីរផែនការរាជធានី ខេត្ត និងមន្ទីរពាក់ព័ន្ធ ដើម្បីអនុវត្ត និងដោះស្រាយបញ្ហានានាក្នុងការអនុវត្តកម្មវិធីនៅថ្នាក់រាជធានី ខេត្ត។

**ប្រការ៩**.-

មេឃុំ ចៅសង្កាត់ ត្រូវដាក់ចេញសេចក្តីសម្រេច ដើម្បីចាត់តាំងឱ្យមានអ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ដើម្បីអនុវត្តកម្មវិធីនៅថ្នាក់ឃុំ សង្កាត់ ស្របតាមសៀវភៅប្រតិបត្តិគោលស្តីពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ។

**ប្រការ១០**.-

រដ្ឋបាលឃុំ សង្កាត់ ទទួលខុសត្រូវលើការចំណាយថ្លៃអ៊ីនធឺណែតសម្រាប់ដំណើរការរបស់តាប្លេតក្នុងការអនុវត្តកម្មវិធី ដោយប្រើប្រាស់កញ្ចប់មូលនិធិ ឃុំ សង្កាត់។

**ប្រការ១១**.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១២.-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធាន មន្ទីរអង្គភាពពាក់ព័ន្ធនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងមហាផ្ទៃ និងក្រសួងផែនការ ព្រមទាំងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះឱ្យមានប្រសិទ្ធភាព តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

សម្តេចក្រឡាហោម ស ខេង

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

កិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន

**រដ្ឋមន្ត្រី**
**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន**
**និងយុវនីតិសម្បទា**

វង សូត

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រុមប្រឹក្សាជាតិគាំពារសង្គម
- រដ្ឋបាលរាជធានី ខេត្ត

"ដើម្បីជ្រាប"
- ដូចប្រការ១២

"ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ